# ជំងឺស្វាយ
# អ្វីដែលអ្នកគួរដឹង

## ជំងឺស្វាយគឺជាប្រភេទជំងឺកាមរោគដែលឆ្លងតាមរយៈការរួមភេទ (STD)។



វាឆ្លងដោយការរួមភេទតាមមាត់ ប្រដាប់ភេទ ឬរន្ធគូទ។ នរណាដែលរួមភេទជាមួយអ្នកដែលមានជំងឺស្វាយ គឺអាចឆ្លងជំងឺនេះបាន។



ស្ត្រីមានផ្ទៃពោះដែលមានជំងឺស្វាយអាចចម្លងជំងឺនេះទៅកាន់ទារកក្នុងផ្ទៃរបស់ពួកគេបាន។



ការធ្វើតេស្តឈាមដោយអ្នកផ្តល់សេវាថែទាំសុខភាព គឺជាវិធីតែមួយគត់ដែលអាចឱ្យអ្នកដឹងថា អ្នកមានជំងឺស្វាយ។



ឱសថសមស្របបានមកពីអ្នកផ្តល់សេវាថែទាំសុខភាព អាចព្យាបាលជំងឺស្វាយបាន។



ការរាតត្បាតនៃជំងឺស្វាយកំពុងតែកើតមាននៅក្នុងខោនធី Pierce និងសហរដ្ឋអាមេរិក។

នៅក្នុងឆ្នាំ2020 ខោនធី Pierce មានជំងឺស្វាយចំនួន 277 ករណី។ នៅក្នុងឆ្នាំ2021 មានចំនួន 554 ករណី។

មានទារកកាន់តែច្រើនដែលកើតមកមានជំងឺស្វាយពីកំណើតជារៀងរាល់ឆ្នាំ។

## ប្រសិនបើអ្នកទទួលការព្យាបាលជំងឺស្វាយ រាល់ដៃគូរួមភេទរបស់អ្នកទាំងអស់ក៏ត្រូវតែទទួលការព្យាបាលក្នុងពេលជាមួយគ្នានោះដែរ។



សូមធ្វើតាមការណែនាំចំពោះរយៈពេលដែលអ្នកមិនអាចរួមភេទបានក្រោយការព្យាបាល។



ប្រសិនបើអ្នកទទួលបានការព្យាបាលជំងឺស្វាយហើយ វាជាសះស្បើយ អ្នកក៏អាចឆ្លងជំងឺនេះម្តងទៀតប្រសិនបើអ្នករួមភេទជាមួដយនឹងអ្នកដែលមានជំងឺស្វាយ។

## មនុស្សជាច្រើនដែលមានជំងឺស្វាយមិនកត់សម្គាល់ឃើញរោគសញ្ញាទេ។

អ្នកខ្លះអាចនឹងកត់សម្គាល់ឃើញរោគសញ្ញាដូចជា៖







- ហើមកូនកណ្តុរ
- គ្រុនក្តៅ
- ឈឺសាច់ដុំ ឬសន្លាក់
- មានការប្រែប្រួលគំហើញ ឬការស្តាប់។

- ជ្រុះសក់ កន្ទួល ដំបៅ ឬដុំពកដូចឬសនៅលើប្រដាប់ភេទ។តែនឹងបាត់ទៅវិញ ទោះបីជាមិនទទួលបានការព្យាបាលក៏ដោយ។

## បើគ្មានការព្យាបាលត្រឹមត្រូវ ជំងឺស្វាយអាចបង្កឱ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរ ឬឈានដល់ការបាត់បង់ជីវិត។





## អ្នកមានសំណួរដែរទេ? ចង់បានព័ត៌មានបន្ថែមដែរទេ?

សូមពិភាក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

ប្រសិនបើអ្នកមិនមានអ្នកផ្តល់សេវាថែទាំសុខភាពនោះទេ សូមហៅទូរស័ព្ទទៅកាន់គ្លីនិកសុខភាពផ្លូវភេទនៃនាយកដ្ឋានសុខភាពខោនធី Tacoma-Pierce តាមរយៈលេខ (253) 649-1418។ ស្វែងរកព័ត៌មានបន្ថែមអំពីរោគស្វាយ និងជំងឺកាមរោគ STD ផ្សេងទៀតនៅលើ cdc.gov/std។